**អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា**

**អគ្គនាយកដ្ឋានស្រាវជ្រាវ**

**នាយកដ្ឋានស្រាវជ្រាវថវិកា**

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- World Bank ព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា កើនឡើង២,២%ឆ្នាំ២០២១ និង ៤,៥%ឆ្នាំ២០២២
- វិស័យអចលនទ្រព្យនឹងប្រសើរឡើង ក្រោយការបើកវិស័យទេសចរណ៍
- គិតត្រឹមរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២១ ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា និងថៃមានការកើនឡើង
- កម្ពុជា ជាប្រទេសទី១នៅអាស៊ីប៉ាស៊ីហ្វិក ដែលទទួលបានកម្មវិធីដើម្បីភាពជាដៃគូប្រទេស
- ជំនួបធុរកិច្ចរវាងកម្ពុជា-តួកគី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងតភ្ជាប់ទំនាក់ទំនងវិនិយោគ
- សំណើ ៣ចំណុច ដាក់ទៅធនាគារពិភពលោក ឱ្យមានស្តង់ដារនាំចេញកសិផលកម្ពុជា
- មានការលើកឡើងថា ការជំរុញការធ្វើកសិ-ពាណិជ្ជកម្ម ជារឿងលំបាកមួយសម្រាប់កម្ពុជា
- ការនាំចេញទំនិញវៀតណាមមកកាន់កម្ពុជាបានកើនឡើង១៦,៧%ក្នុងរយៈពេលប្រាំបីខែដំបូង
- រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុថៃ នៅតែរំពឹងថាផ.ស.ស. នឹងមានកំណើន ១,៣% នៅក្នុងឆ្នាំ២០២១
- ពលរដ្ឋសិង្ហបុរី១៦ម៉ឺននាក់ នឹងទទួលបានកាតទិញគ្រឿងទេសតម្លៃ១០០ដុល្លារសិង្ហបុរី នៅខែតុលា នេះ
- កំណើននៃវិស័យសំណង់របស់ម៉ាឡេស៊ី នៅក្នុងត្រីមាស ទី២ ឆ្នាំ២០២១
- កំណើនការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេងរបស់សិង្ហបុរីទៅកាន់ទីផ្សារធំៗទាំង១០នៅក្នុងខែសីហា
- ម៉ាឡេស៊ី ដាក់ផែនការសេដ្ឋកិច្ច៥ឆ្នាំ ដើម្បីក្លាយជាប្រទេសមានប្រាក់ចំណូលខ្ពស់
- ធនាគារកណ្តាលរក្សាអត្រាការប្រាក់ឱ្យមានស្ថិរភាព
- ប្រេងឆៅ Brent លោតដល់ជាង ៨០$ ជាកម្រិតតខ្ពស់បំផុតក្នុងកំឡុងជិត ៣ឆ្នាំ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា សប្តាហ៍ទី១ ខែតុលា ឆ្នាំ២០២១ លេខ ៖ ៨៧

# ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

## World Bank ព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា កើនឡើង២,២%ឆ្នាំ២០២១ និង ៤,៥% នៅឆ្នាំ២០២២




*ប្រភព ៖ freshnewsasia*

ធនាគារពិភពលោក (World Bank)បានចេញរបាយការណ៍មួយ ដោយបានកែសម្រួលការព្យាករណ៍ កំណើនសេដ្ឋកិច្ចកម្ពុជា សម្រាប់ឆ្នាំ២០២១ មកនៅត្រឹម២,២% និងឆ្នាំ២០២២កើនឡើង៤,៥%។

របាយការណ៍របស់ធនាគារពិភពលោក បានគូសបញ្ជាក់ថា ទស្សនៈវិស័យរបស់កម្ពុជានៅតែមានភាពមិនច្បាស់លាស់ខ្ពស់ ទោះបីការចាក់វ៉ាក់សាំង មានវឌ្ឍនភាពលឿនលឿនក៏ដោយ ហានិភ័យនៃការផ្ទុះឡើងនៃការឆ្លងដែលអូសបន្លាយ និងការរាំងស្ទះ បន្តនៅតែមានកម្រិតខ្ពស់ ដោយសារការឆ្លង និងស្លាប់បន្តមានចំនួនច្រើន។ ប្រទេសកម្ពុជា កំពុងប្រឈមនឹងការកើនឡើងវិញ នូវករណីឆ្លងជំងឺកូវីដ-១៩ ដែលបានធ្វើឱ្យការស្តារសេដ្ឋកិច្ច មានភាពយឺតយ៉ាវ ជាពិសេសវិស័យសេវាកម្មសំណង់ និងអចលនទ្រព្យ។

សូមរំលឹកថា កាលពីថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ ធនាគារពិភពលោក (World Bank) បានព្យាករណ៍ថា សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា នឹងបន្តកើនឡើង ក្នុងអត្រា៥,២% នៅក្នុងឆ្នាំ២០២២ និងក្នុងឆ្នាំ២០២៣ ស្របពេលដែលនៅក្នុងឆ្នាំ២០២១នេះ សេដ្ឋកិច្ចនឹងបន្តកើនឡើង ក្នុងអត្រា៤%។ ប៉ុន្តែនៅពេលនេះ ធនាគារនេះបានព្យាករណ៍ការកើនឡើននៃសេដ្ឋកិច្ច មកត្រឹម ២,២% ក្នុងឆ្នាំ២០២១ និង ៤,៥% នៅឆ្នាំ២០២២៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnewsasia ចេញផ្សាយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។*

## វិស័យអចលនទ្រព្យនឹងប្រសើរឡើង ក្រោយការបើក វិស័យទេសចរណ៍



*រូបភាព៖ ខេមបុណ្ណមីស*

ការបើកតំបន់ទេសចរណ៍ ទទួលភ្ញៀវទេសចរបរទេសបានចាក់វ៉ាក់សាំងកូវីដ-១៩ រួច ដែលគ្រោងធ្វើឡើងនៅចុងឆ្នាំនេះ ជាដង្ហើមសេដ្ឋកិច្ចដ៏សំខាន់មួយសម្រាប់កម្ពុជា។ គម្រោងបើកទទួលភ្ញៀវទេសចរបរទេសដំណាក់កាលដំបូង គឺជាការផ្តល់ក្តីសង្ឃឹមឡើងវិញសម្រាប់អាជីវកម្មទេសចរណ៍ និងក៏ឈានទៅស្តារវិស័យអចលនទ្រព្យ និងវិស័យដែលរងផលប៉ះពាល់ដោយ

កូវីដ-១៩ ហើយវាក៏នឹងក្លាយជាចរន្តនាំវិនិយោគិនបរទេសឱ្យមកបោះទុនវិនិយោគនៅកម្ពុជាផងដែរ។

កន្លងមកវិស័យទេសចរណ៍មិនត្រឹមតែធ្វើឱ្យអាជីវកម្មដូចជាភោជណីយដ្ឋាន អាហារដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ និងសេវាកម្មទេសចរណ៍ផ្សេងៗមានការរីកដុះដាលប៉ុណ្ណោះទេ តែវាក៏ជាផ្នែកមួយក្នុងការជួយទាក់ទាញវិនិយោគិនបរទេសឱ្យមកវិនិយោគនៅកម្ពុជាផងដែរ។

វិស័យអចលនទ្រព្យកម្ពុជា ជាវិស័យដ៏សំខាន់ក្នុងការជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ ប៉ុន្តែវិស័យនេះមិនអាចរីកចម្រើនលូតលាស់ដោយខ្លួនឯងបាននោះទេ គឺត្រូវពឹងផ្អែកលើវិស័យអាទិភាពមួយចំនួនដូចជាវិស័យទេសចរណ៍ ពាណិជ្ជកម្ម ការវិនិយោគ និងវិស័យសហគ្រាសធុនតូច និងមធ្យមជាដើម។ វិស័យអចលនទ្រព្យនៅកម្ពុជានៅក្នុងរយៈពេលជិត៩ខែកន្លងមកនេះនៅតែមានចរន្តទិញលក់ ទោះបីមានការរំខានពីជំងឺកូវីដ-១៩។ ហើយតម្លៃអចលនទ្រព្យទៀតសោត ក៏ពុំមានការប្រែប្រួលគួរឱ្យកត់សម្គាល់ផងដែរ។
អ្នកជំនាញសេដ្ឋកិច្ច និងអចនទ្រព្យអះអាងថា វិស័យសេដ្ឋកិច្ច និងអចលនទ្រព្យនៅខេត្តព្រះសីហនុ នឹងមានភាពរីកចម្រើនឡើងវិញមួយកម្រិត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា ជ្រើសរើសយកខេត្តនេះធ្វើជាគោលដៅ នៃការបើកតំបន់ទេសចរណ៍ទទួលភ្ញៀវទេសចរបរទេសបានចាក់វ៉ាក់សាំងរួចនៅចុងឆ្នាំនេះ៕
*ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូណូមីសចេញផ្សាយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។*

## UN និង UNWTO: ការអភិវឌ្ឍទេសចរណ៍ពិភពលោកបន្ទាប់វិបត្តិកូវីដ ត្រូវរុញឱ្យដល់មូលដ្ឋានជនពិការ ជនជាតិភាគតិច និងស្ត្រីជាដើម



*ប្រភព ៖ freshnewsasia*

នាឱកាសទិវាទេសចរណ៍ពិភពលោក ខួបលើកទី៤១ ឆ្នាំ២០២១ អគ្គលេខាធិការអង្គការសហប្រជាជាតិ ក៏ដូចជា អគ្គលេខាធិការអង្គការទេសចរណ៍ពិភពលោក បានគូសបញ្ជាក់ ពីការអភិវឌ្ឍទេសចរណ៍ប្រកបដោយបរិយាបន្ន ការស្តារកំណើនទេសចរណ៍ និងការបើកទទួលទេសចរណ៍ឡើងវិញ ដែលជាការអភិវឌ្ឍទេសចរណ៍ពិភពលោកបន្ទាប់ពីវិបត្តិកូវីដ-១៩ ត្រូវរុញឱ្យដល់មូលដ្ឋានជនពិការ ជនជាតិភាគតិច ក៏ដូចជាស្ត្រីជាដើម។

ជាការកត់សម្គាល់ក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ គឺមានតែទេសចរណ៍មួយប៉ុណ្ណោះ ដែលជាវិស័យដែលបានផ្តល់ផលប្រយោជន៍ ទៅដល់គ្រប់បណ្តាជនដែលងាយរងគ្រោះ និងដែលត្រូវបានមើលរំលង ដូចជា ជនមានពិការភាព ជនជាតិភាគតិច និងស្ត្រីជាដើម។ ប្រឈមមុខនឹងវិបត្តិកូវីដ-១៩នេះ បណ្តាជនទាំងនេះជាអ្នកកំពុងទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរខ្លាំងបំផុត។

ជាការដាស់តឿន របស់អគ្គលេខាធិការអង្គការទាំងពីរខាងលើ ស្របតាមពេលវេលា និងភាពចាំបាច់ ពេល

នេះជាពេលដែលត្រូវគិតសារជាថ្មី ផ្លាស់ប្តូរ និងចាប់ផ្តើមបើកវិស័យទេសចរណ៍ឡើងវិញប្រកបដោយសុវត្ថិភាព ដើម្បីចូលរួមជួយដល់ការកសាងសេដ្ឋកិច្ច និងសង្គមប្រកបដោយភាពធន់ និរន្តរភាព សមភាពយេនឌ័រ និងបរិយាបន្ន សម្រាប់មនុស្សគ្រប់គ្នាឆ្ពោះទៅរកទេសចរណ៍បៃតង និងរក្សាលំនឹងកាបូន (C)។

នាឱកាសនោះ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ក៏បានប្រកាសផ្តល់អាហារូបករណ៍ចំនួន ៥០ កន្លែង ដែលផ្តល់ដោយអង្គការទេសចរណ៍ពិភពលោក(UNWTO)ដល់កម្ពុជា ដែលជាកម្មវិធីជួយស្តារវិស័យទេសចរណ៍ប្រទេសសមាជិកឡើងវិញ ដល់ផ្នែកឯកជន និងសិស្សនិស្សិត គឺផ្តោតលើ៖

១៖ យុទ្ធសាស្ត្រធុរកិច្ច
២៖ គណនេយ្យ និងហិរញ្ញវត្ថុ
៣៖ មូលដ្ឋានគ្រឹះនៃទីផ្សារឌីជីថល
៤៖ មូលដ្ឋានគ្រឹះនៃការគ្រប់គ្រងប្រតិបត្តិករ
៥៖ មូលដ្ឋានគ្រឹះនៃនវានុវត្តន៍ និងការផ្លាស់ប្តូរឌីជីថល។

*ដោយ ម៉ែនខែមរៈ*

*ប្រភព៖ freshnewsasia ចេញផ្សាយថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១។*

## កម្ពុជា ជាប្រទេសទី១នៅអាស៊ីប៉ាស៊ីហ្វិក ដែលទទួលបានកម្មវិធីដើម្បីភាពជាដៃគូប្រទេស

### (Programme for Country Partnership-PCP)




*ប្រភព ៖ SWIFT NEWS*

កម្ពុជា ជាប្រទេសទី១នៅអាស៊ីប៉ាស៊ីហ្វិកទទួលបានកម្មវិធីដើម្បីភាពជាដៃគូប្រទេស (Programme for Country Partnership-PCP) ពីអង្គការសហប្រជាជាតិដើម្បីជួយគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ២០១៥-២០២៥ របស់រាជរដ្ឋាភិបាល ក្នុងគោលបំណងសម្រេចបានគោលដៅអភិវឌ្ឍន៍ឧស្សាហកម្មប្រកបដោយចីរភាព និងបរិយាប័ន (Inclusive and Sustainable Industrial Development-ISID) ដែលជាគោលដៅអភិវឌ្ឍទី៩ របស់អង្គការសហ-ប្រជាជាតិ។

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានអង្គភាពសម្របសម្រួលថ្នាក់ជាតិបានឱ្យដឹងថា កម្មវិធីដើម្បីភាពជាដៃគូប្រទេសនេះ គ្របដណ្តប់លើផ្នែកធំ២ និងផ្នែកអន្តរវិស័យចំនួន៥ រួមមាន ផ្នែកទី១ ស្តីអំពីការអភិវឌ្ឍខ្សែសង្វាក់តម្លៃកសិកម្ម រួមទាំងការភ្ជាប់ជាមួយវិស័យទេសចរណ៍ និងផ្នែកទី២ ស្តីអំពីការធ្វើពិពិធកម្មឧស្សាហកម្ម ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងនវានុវត្តន៍ រួមទាំងផ្នែកអន្តរវិស័យមួយចំនួន ដែលចែកចេញជា៣៖ (១) វិស័យសេដ្ឋកិច្ច ដែលក្នុងនោះមានគោលនយោបាយឧស្សាហកម្ម និងស្ថិតិ និងហេដ្ឋារចនាសម្ព័ន្ធគុណភាព (២) វិស័យបរិស្ថាន ដែលក្នុងនោះមានថាមពលប្រកបដោយចីរភាព និងសេដ្ឋកិច្ចចក្រា (Circular Economy) និង (៣) ផ្នែកសង្គម ដែលក្នុងនោះមាន ការផ្តល់អំណាចទៅស្ត្រី និងការបង្កើតការងារជូនយុវជន។ ថវិកាសរុបនៃកម្មវិធីដើម្បីភាពជាដៃគូប្រទេស ២០២០-២០២៣នេះ ត្រូវបានប៉ាន់ស្មានប្រមាណជាង ៦០លានដុល្លាសហរដ្ឋអាមេរិក។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានផ្តល់អនុសាសន៍ណែនាំដល់សមាជិកក្រុមការងារលេខាធិការដ្ឋាន និងជាពិសេសក្រុមការងារភាពជាដៃគូ និងដៃគូអភិវឌ្ឍន៍ (PDWG) ទាំងអស់ឱ្យយកចិត្តទុកដាក់អនុវត្តការងារតាមតួនាទី និងភារកិច្ចបានប្រគល់ជូន ដើម្បីអនុវត្តកម្មវិធី PCP ២០២០-២០២៣ ទទួលបានជោគជ័យ។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ SWIFT NEWS ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១។*

## ជំនួបធុរកិច្ចរវាងកម្ពុជា-តួកគី ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងតភ្ជាប់ទំនាក់ទំនងវិនិយោគ




*ប្រភព ៖ CEN*

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសតួកគី និងក្រុមការងារសម្របសម្រួលការទូតសេដ្ឋកិច្ច ដោយសហការជាមួយសភាពាណិជ្ជកម្មកម្ពុជា និងសហព័ន្ធអ្នកជំនួញឧស្សាហកម្មតួកគី SANKON បានរៀបចំ "ជំនួបធុរកិច្ចរវាងកម្ពុជា-តួកគី" ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងតភ្ជាប់ទំនាក់ទំនង រវាងវិនិយោគិន និងធុរជនកម្ពុជា និងតួកគី។

ជំនួបធុរកិច្ចនេះ ផ្តោតលើប្រធានបទសំខាន់មួយចំនួនដូចជា៖ ពាណិជ្ជកម្ម កសិ-ឧស្សាហកម្ម វាយនភ័ណ្ឌ សំណង់ ទេសចរណ៍ អប់រំ ព័ត៌មានវិទ្យា គ្រឿងសង្ហារឹម និងវិស័យសំខាន់ៗមួយចំនួនទៀត។

គោលបំណងជំនួបធុរកិច្ចនេះ គឺដើម្បីជួយត្រួសត្រាយផ្លូវដល់ធុរជន និងវិនិយោគិនតួកគី អាចស្វែងយល់ពីឱកាសទីផ្សារ និងការវិនិយោគនៅកម្ពុជា ក៏ដូចជាជួយពង្រឹង កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មរវាងប្រទេសទាំងពីរ។

អនុប្រធានសភាពាណិជ្ជកម្មកម្ពុជា បានលើកឡើងថា ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និងតួកគី នៅមានទំហំតូចនៅឡើយ។ នៅឆ្នាំ២០២០ ទំហំពាណិជ្ជកម្មសរុបមានប្រមាណ ៨៨,៨លានដុល្លារ។ កម្ពុជាបាននាំចេញទៅកាន់តួកគី ក្នុងទំហំទឹកប្រាក់ ៣៥លានដុល្លារ។ រដ្ឋាភិបាលនៃប្រទេសទាំងពីរប្តេជ្ញាបង្កើនពាណិជ្ជកម្មទ្វេភាគីឱ្យដល់ ៥០០លានដុល្លារអាមេរិក នាឆ្នាំខាងមុខ។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ CEN ចេញផ្សាយថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១។*

## សំណើ ៣ចំណុច ដាក់ទៅធនាគារពិភពលោក ឱ្យមានស្តង់ដារនាំចេញកសិផលកម្ពុជា




*ប្រភព ៖ SWIFT NEWS*

ថ្មីៗនេះ ក្រសួងកសិកម្ម បានទទួលជួបជាមួយនាយកគ្រប់គ្រងធនាគារពិភពលោកថ្មីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារសំខាន់ៗ សំដៅដល់ការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព និងជាពិសេសក្នុងបរិបទនៃការរីករាលដាលជំងឺឆ្លងកូវីដ-១៩។

កន្លងមកធនាគារពិភពលោក បានជួយឧបត្ថម្ភគាំទ្រដល់គម្រោងអភិវឌ្ឍវិស័យកសិកម្ម ដែលគម្រោងទាំងអស់នោះ បាននិងកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាព និងមាននិរន្តរភាពនៃកំណើនសេដ្ឋកិច្ចគ្រួសារ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាសមស្រប ការធ្វើពិពិធកម្មកសិកម្ម ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ការធានាសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការពង្រីកសក្តានុពលផលិតកម្មតាមរយៈការអនុវត្តបច្ចេកវិទ្យាទំនើបទាន់សម័យ ធននឹងការប្រែប្រួលអាកាសធាតុ បរិយាប័ន្ន និងនវានុវត្តន៍ សំដៅឈានទៅសម្រេចឱ្យបាននូវចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការនាំចេញកសិផលទៅកាន់ទីផ្សារអន្តរជាតិ។

នៅក្នុងជំនួបនេះ ឯកឧត្តមរដ្ឋមន្ត្រីបានលើកសំណើជូនលោកជំទាវនាយកគ្រប់គ្រងធនាគារពិភពលោក ធ្វើការពិនិត្យពិចារណានូវលទ្ធភាពដល់ការគាំទ្រលើគម្រោងសំខាន់០៣ ដូចខាងក្រោម៖

ទី១- ការពង្រឹងផលិតភាពផលិតកម្មបន្លែនៅទូទាំងប្រទេស និងដោយឡែកក្នុងតំបន់ជុំវិញរាជធានីភ្នំពេញ ដើម្បីធានាបរិមាណផ្គត់ផ្គង់ គុណភាព សុវត្ថិភាព និងតម្លៃ ដោយធ្វើការចងក្រងបណ្តុំផលិត តភ្ជាប់ជាមួយបណ្តាញទីផ្សារ កន្លែងប្រមូលផ្តុំ រចនាសម្ព័ន្ធស្តុក និងការដឹកជញ្ជូន។

ទី២- បន្តធ្វើទំនើបកម្មវិស័យកសិកម្ម និងកែលម្អហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ដំណាំផ្លែឈើ ការកែច្នៃ និងការនាំចេញ សេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្ម ការសិក្សាស្រាវជ្រាវ និងផលិតពូជ សំដៅបង្កើនទិន្នផល ការគ្រប់គ្រង និងការប្រើប្រាស់ជី ថ្នាំកសិកម្ម ព្រមទាំងការកសាង និងពង្រឹងសមត្ថភាពធនធានមនុស្ស និងសមត្ថភាពមន្ទីរពិសោធន៍ជាតិ។

ទី៣- ការអភិវឌ្ឍវិស័យវារីវប្បកម្ម ពង្រឹង និងពង្រីកការងារស្រាវជ្រាវ ការបង្កាត់ និងផ្សព្វផ្សាយពូជត្រី និងចំណីឱ្យបានទូលំទូលាយ រួមទាំងការបណ្តុះបណ្តាលធនធានមនុស្សផងដែរ។

ក្នុងការឆ្លើយតប នាយកគ្រប់គ្រងធនាគារពិភពលោក បានបញ្ជាក់ថា នឹងយកសំណើនេះទៅពិនិត្យពិចារណាឱ្យបានលម្អិតជាមួយក្រុមជំនាញ និងដៃគូពាក់ព័ន្ធផ្សេងទៀត ហើយសង្ឃឹមថាធនាគារនឹងបន្តកិច្ចសហការឱ្យកាន់តែរឹងមាំជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាន់តែល្អប្រសើរ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖SWIFTNEWS ចេញផ្សាយថ្ងៃទី១៥ខែកញ្ញាឆ្នាំ២០២១។*

## ឯកឧត្តម ឧកញ៉ាបណ្ឌិត ម៉ុង ឫទ្ធី លើកឡើងថា ការជំរុញធ្វើកសិ-ពាណិជ្ជកម្ម ជារឿងលំបាកមួយសម្រាប់កម្ពុជា



*ប្រភព ៖ ខេមបូណ្ឌាមីស*

ជាអ្នកជំនាញកសិកម្ម និងជាអគ្គនាយកនៃក្រុមហ៊ុនម៉ុង ឫទ្ធី គ្រុប ឯកឧត្តម ឧកញ៉ាបណ្ឌិត ម៉ុង ឫទ្ធីយល់ឃើញថា បើទោះបីកម្ពុជាជាប្រទេសកសិកម្មក៏ពិតមែន តែការប្រែក្លាយកម្ពុជា ទៅជាប្រទេសកសិ-ពាណិជ្ជកម្ម មិនមែនជារឿងងាយស្រួលទេ។ សម្រាប់កម្ពុជា ការជំរុញធ្វើកសិ-ពាណិជ្ជកម្ម មានកត្តាសំខាន់ៗជាច្រើន

ក្នុងនោះ កត្តាពូជ ជាកត្តាចម្បងបំផុតមួយក្នុងការឈានទៅជំរុញការធ្វើកសិ-ពាណិជ្ជកម្ម។ រហូតមកដល់ពេលនេះ កម្ពុជានៅតែមានការនាំចូលកសិផលពីក្រៅប្រទេស នោះក៏ព្រោះតែការផ្គត់ផ្គង់របស់កម្ពុជា មិនទាន់គ្រប់គ្រាន់ ពិសេស គឺការផ្គត់ផ្គង់ពូជ ដែលកម្ពុជាមិនទាន់មានលទ្ធភាពគ្រប់គ្រាន់ សម្រាប់ផ្គត់ផ្គង់ខ្លួនឯង ដូច្នេះ ការជំរុញវិស័យកសិ-ពាណិជ្ជកម្ម អាចពិបាក និងត្រូវប្រើពេលបន្ថែមទៀត។ ដោយឡែក ចំពោះទីផ្សារកសិកម្មកម្ពុជា គឺមានស្ថានភាពល្អ។
វិស័យកសិកម្ម គឺស្ថិតនៅក្នុងចំណោមវិស័យឆ្អឹងខ្នងសេដ្ឋកិច្ចរបស់កម្ពុជា ហើយវាជាវិស័យមួយធន់ជាងគេនៅអំឡុងពេលប្រទេសកំពុងជួបបញ្ហាវិបត្តិកូវីដ-១៩ និងកំពុងដើរតួនាទីកាន់តែសំខាន់។

តួលេខពីក្រសួងកសិកម្មបង្ហាញថា នៅ៨ខែដំបូងនៅឆ្នាំ២០២១ កម្ពុជាសម្រេចបានការនាំចេញផលិតផលកសិកម្មជាង៥លានតោន កើនឡើងដល់ទៅជាង៨៩% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ តាមការព្យាករពីធនាគារអភិវឌ្ឍន៍អាស៊ី វិស័យកសិកម្មរបស់កម្ពុជានៅឆ្នាំ២០២១នេះ នឹងកើនឡើង ១,៥% នៅគ្រាដែលសេដ្ឋកិច្ចកម្ពុជាត្រូវបានព្យាករដែរថា នឹងកើន១,៩%នៅឆ្នាំ២០២១៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ខេមបូណូមីស ចេញផ្សាយថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២១។*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថានឹងទទួលបានកំណើនវិជ្ជមាន

យោងតាមរបាយការណ៍ប្រចាំឆមាសទី១ របស់ធនាគារជាតិនៃកម្ពុជាបានបង្ហាញថា៖ កំណើនសេដ្ឋកិច្ចកម្ពុជានឹងវិជ្ជមានក្នុងឆ្នាំ២០២១ និងឆ្នាំ២០២២ បើតាមការប៉ាន់ស្មានរបស់ស្ថាប័នមួយចំនួនដូចក្នុងតារាងខាងក្រោម៖

### តារាងទី១៖ ការព្យាករកំណើនសេដ្ឋកិច្ចកម្ពុជារបស់ស្ថាប័នអន្តរជាតិ

| | ឆ្នាំ២០២១ព | ឆ្នាំ២០២២ព |
|---|---|---|
| មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) | ៤,២% | ៦,០% |
| ធនាគារពិភពលោក(WB) | ៤,០% | ៥,២% |
| ធនាគារអភិវឌ្ឍន៍អាស៊ី(ADB) | ៤,០% | ៥,៥% |
| អង្គភាព AMRO | ៣,៥% | ៦,៤% |
| រាជរដ្ឋាភិបាល | ៤,០% | ៥,៧% |

ប្រភព៖ ធនាគារជាតិ នៃកម្ពុជា(ព=ព្យាករ)

ក្នុងឆ្នាំ២០២០ សេដ្ឋកិច្ចកម្ពុជាមានកំណើនថយចុះដល់ -៣,១%។

សេដ្ឋកិច្ចកម្ពុជា ត្រូវបានប៉ាន់ស្មានថានឹងទទួលបានកំណើនវិជ្ជមានប្រហែល៤% ក្នុងឆ្នាំ២០២១ ប៉ុន្តែកំណើននេះ អាចមានកម្រិតទាបជាងការរំពឹងទុកកាលពីចុងឆ្នាំ២០២០។ យោងតាមការប៉ាន់ស្មានរបស់ IMF, WB, ADB និងអង្គភាព AMRO សេដ្ឋកិច្ចកម្ពុជាអាចសម្រេចបានកំណើនក្នុងអត្រាពី ៣,៥% ទៅ ៤,២% ក្នុងឆ្នាំ២០២១ និងពី៥,២% ទៅ ៦,៤% សម្រាប់ឆ្នាំ២០២២៕ ***ដោយ ឈន ហ៊ា***

*ប្រភព៖ ធនាគារជាតិ នៃកម្ពុជា,ថ្ងៃទី៣ ខែកញ្ញា ឆ្នាំ២០២១*

### រូបភាព៖ ការដកសាច់ប្រាក់ពីរដ្ឋតាមវិស័យ ប្រចាំឆ្នាំ ឆមាស និងសរុបត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០២១

យោងតាមព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជាដែលចេញផ្សាយដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបាន

បង្ហាញថា ការដកសាច់ប្រាក់ ក្នុងក្របខ័ណ្ឌការផ្តល់ឥណទានរបស់រដ្ឋតាមវិស័យដោយឥណាយិក ដើម្បីយកទៅប្រើប្រាស់សម្រាប់កសាងហេដ្ឋានចនាសម្ព័ន្ធរូបវន្ត សរុបមានចំនួនប្រមាណ ១២៦ លានដុល្លារអាមេរិកក្នុងឆមាសទី១ ឆ្នាំ២០២១។ ចំណែកវិស័យអាទិភាពចំពោះមុខផ្សេងទៀតពុំបានដកចំណាយទេក្នុងឆ្នាំ២០១៩, ឆ្នាំ២០២០ និងឆមាសទី១ ឆ្នាំ២០២១។ ការដកប្រាក់ក្នុងឆមាសទី១ ឆ្នាំ២០២១ ស្មើនឹង ៣៤%, ៤៥% រៀងគ្នា បើធៀបនឹងឆ្នាំ២០១៩ និងឆ្នាំ២០២០។

រូបភាពទី១៖ ការដកសាច់ប្រាក់ពីរដ្ឋតាមវិស័យហេដ្ឋារចនាសម្ព័ន្ធក្នុងឆមាសទី១ ឆ្នាំ២០២១




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ(S1=ឆមាសទី១)

រូបភាពទី២៖ សរុបត្រឹមដំណាច់ឆមាសទី១ ឆ្នាំ២០២១




ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

បើគិតចាប់ពីឆ្នាំ១៩៩៣ រហូតមកដល់ដំណាច់ឆមាសទី១ ឆ្នាំ២០២១(ក្រាហ្វទី២) ឥណាយិកបានដកសាច់ប្រាក់សរុបចំនួន ២,២២ ប៊ីលានដុល្លារអាមេរិកស្មើនឹង ៧០% នៃការផ្តល់ឥណទាន ដែលបានចុះកិច្ចព្រមព្រៀង ក្នុងនោះ៖ ៩៩% ត្រូវបានប្រើប្រាស់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ១% ទៀតក្នុងវិស័យអាទិភាពចំពោះមុខផ្សេងទៀត។ *ដោយ ឈន ហាំ*

ប្រភព៖ <u>របាយការណ៍ឆមាសទី១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០២១</u>

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### គិតត្រឹមរយៈពេលប្រាំបីខែដំបូងនៃឆ្នាំ២០២១ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសកម្ពុជា និងប្រទេសថៃមានការកើនឡើង



*ប្រភព៖ khmertimes, 2021 រូបភាព៖ Chea Vanyuth*

យោងតាមការបង្ហាញទិន្នន័យរបស់ក្រសួងពាណិជ្ជកម្មនៃប្រទេសថៃ បានបង្ហាញថា៖ ពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជានិងថៃមានតម្លៃ ៥,២ប៊ីលានដុល្លារក្នុងរយៈពេល ៨ ខែដំបូងនៃឆ្នាំនេះកើនឡើង ៣,១៤%បើប្រៀបធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

នៅក្នុងរយៈពេល០៨ខែនេះ ប្រទេសកម្ពុជាបាននាំចេញផលិតផលមានតម្លៃ ៦២៣ លានដុល្លារទៅកាន់ប្រទេសថៃដែលមានការថយចុះ ៣១,៧%និងសម្រាប់ការនាំចូលរបស់ប្រទេសកម្ពុជាពីប្រទេសថៃវិញបាន

កើនឡើង ១០,៧% ស្មើនឹង ៤,៦ប៊ីលានដុល្លារធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

ការនាំចេញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសថៃគឺជាផលិតផលកសិកម្មដែលមានចំណែកភាគច្រើននៃការនាំចេញ ខណៈការនាំចេញរបស់ថៃមកកម្ពុជាមានធនធានថាមពល ជីកសិកម្ម វត្ថុធាតុចំណីអាហារ និងគ្រឿងសំអាង។ ផលិតផលរបស់កម្ពុជា ដែលភាគច្រើនជាផលិតផលកសិកម្មដែលត្រូវបាននាំចេញទៅប្រទេសថៃតែងតែត្រូវបានរំខានដោយរបាំងនៃលក្ខខណ្ឌអនាម័យ និងភូតគាមអនាម័យ។ កាលពីខែសីហា ប្រទេសថៃបានហាមឃាត់ការនាំចេញផ្លែមៀនប៉ៃលិនពីប្រទេសកម្ពុជា ដោយសារតែការហាមឃាត់របស់ចិនលើក្រុមហ៊ុននាំចេញផលិតផលកសិកម្មរបស់ថៃទៅកាន់ប្រទេសចិន។

នៅពេលថៃហាមឃាត់កម្ពុជាមិនឱ្យនាំចេញផ្លែមៀនប៉ៃលិន ក្រសួងកសិកម្មបានជំរុញឱ្យមានការពិភាក្សាជាមួយចិន ហើយរដ្ឋាភិបាលចិនបានឆ្លើយតបជាវិជ្ជមាននិងភ្លាមៗ។ តាមរយៈកិច្ចពិភាក្សានេះ កម្ពុជាសង្ឃឹមថាកម្ពុជានឹងឈានដល់ការចុះពិធីសារស្តីពីផលិតផលកសិកម្មជាច្រើនសម្រាប់ការនាំចេញ។

ប្រទេសទាំងពីរបានដាក់ក្តីសង្ឃឹមខ្ពស់ក្នុងការបន្តជំរុញពាណិជ្ជកម្មទ្វេភាគីរហូតដល់ ១៥ប៊ីលានដុល្លារនៅឆ្នាំ២០២៣ ។ ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរមានតម្លៃ ៧,២ ប៊ីលានដុល្លារកាលពីឆ្នាំមុនធ្លាក់ចុះ ២៣%បើធៀបនឹងឆ្នាំ ២០១៩ ។ ថ្មីៗនេះ ផ្សារទំនើបនៅប្រទេសថៃគឺ Big C និងហាងលក់រាយ 7-Eleven បានបើកដំណើរការហាងរបស់ពួកគេនៅភ្នំពេញ ដែលក្នុងនោះប្រហែល ៧០% ទៅ ៨០%នៃផលិតផលដែលបានបង្ហាញនៅក្នុងទីផ្សារទាំងនោះ គឺជាការនាំចូលពីប្រទេសថៃ ហើយផលិតផលផ្សេងទៀតត្រូវបានផ្គត់ផ្គង់ក្នុងស្រុក៕ *ដោយ សេន ចន្ទី*

*ប្រភព៖khmertimeskh,ចេញផ្សាយថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០២១*

## ការនាំចេញទំនិញវៀតណាមមកកាន់កម្ពុជាបានកើនឡើង ១៦,៧%ក្នុងរយៈពេលប្រាំបីខែដំបូង



*ប្រភព៖khmertimes, 2021*

នៅក្នុងរយៈពេល០៨ខែនេះ ប្រទេសវៀតណាមទទួលបានប្រាក់ចំណូលចំនួន ៣,១៥ប៊ីលានដុល្លារ ពីការនាំចេញទំនិញមកកម្ពុជា ដែលបានកើនឡើង ១៦,៧% ធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំមុន។

ទោះយ៉ាងណាប្រទេសវៀតណាមបានរាយការណ៍ពីឱនភាពពាណិជ្ជកម្មចំនួន ៣៥៤,៤ លានដុល្លារជាមួយកម្ពុជាក្នុងកំឡុងពេលពិនិត្យឡើងវិញ។ មូលហេតុមួយនៅពីក្រោយឱនភាពពាណិជ្ជកម្ម គឺការកើនឡើងនៃការនាំចូលផលិតផលសំខាន់ៗចំនួន៦ ពីកម្ពុជាបើធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដោយការនាំចូលគ្រាប់ស្វាយចន្ទីនិងកៅស៊ូមានការកើនឡើងខ្ពស់បំផុត។ ប្រទេសវៀតណាមបានចំណាយជិត ១,៨៣ប៊ីលានដុល្លារក្នុងការនាំចូលគ្រាប់ស្វាយចន្ទីពីកម្ពុជាក្នុងរយៈពេល ៨ខែដំបូង ដែលជាការកើនឡើង៧ដងធៀបនឹងឆ្នាំមុនៗ។ ទន្ទឹមនឹងនេះ ការនាំចូលកៅស៊ូរបស់វៀតណាមពីប្រទេសជិតខាងមានចំនួនខ្ពស់ជាងតួលេខឆ្នាំមុន ៥ ដង ដែលឆ្នាំមុនមានចំនួនត្រឹម ៨២១,៨ លានដុល្លារ។

ការវិនិយោគរបស់វៀតណាម ដែលបានចុះបញ្ជីនៅកម្ពុជា មានចំនួនជាង ២,៨៥ប៊ីលានដុល្លារជាពិសេស វិស័យកសិកម្មរួមទាំងការដាំដើមស្វាយចន្ទី និងកៅស៊ូ។ អាជីវកម្មវៀតណាមបានវិនិយោគនៅកម្ពុជាដើម្បីទាញយកផលប្រយោជន៍ពីថ្លៃពលកម្មថោកនិងលក្ខខណ្ឌអំណោយផលទាក់ទងនឹងដី អាកាសធាតុ និងការលើកទឹកចិត្ត ហើយបន្ទាប់មកនាំចេញផលិតផលរបស់ពួកគេត្រលប់ទៅប្រទេសវៀតណាមវិញ។ ដើម្បីធ្វើឱ្យមានតុល្យភាពតម្លៃពាណិជ្ជកម្មជាមួយកម្ពុជា វៀតណាមត្រូវការលើកកម្ពស់ការកែច្នៃ កែលម្អ តម្លៃបន្ថែមនៃទំនិញនាំចេញ បង្កើនទិន្នផលនិងគុណភាពគ្រាប់ស្វាយចន្ទី និងកៅស៊ូ និងស្វែងរកការពង្រីកទីផ្សារនាំចេញគ្រាប់ស្វាយចន្ទី និងផលិតផលកៅស៊ូ។

សូមបញ្ជាក់ផងដែរចំពោះការត្រួតពិនិត្យយ៉ាងតឹងរឹងនូវការនាំចូលទំនិញទាំងនេះ គឺដើម្បីធានាបាននូវច្បាប់ប្រភពដើម និងការពង្រឹងការត្រួតពិនិត្យទំនិញដែលនាំចេញទៅវៀតណាមតាមរយៈប្រទេសកម្ពុជា៕

*ដោយ សេន ចន្ទី*

*ប្រភព៖khmertimeskh,ចេញផ្សាយថ្ងៃទី២៨ខែកញ្ញា ឆ្នាំ២០២១*

## រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុថៃ នៅតែរំពឹងថាផ.ស.ស. របស់ប្រទេសថៃនឹងមានកំណើន ១,៣% នៅក្នុងឆ្នាំ២០២១



*រូបភាព៖ REUTERS/Chalinee Thirasupa*

សេដ្ឋកិច្ចថៃ នៅតែត្រូវបានរំពឹងថានឹងមានកំណើនក្នុងអត្រា ១,៣% នៅឆ្នាំ២០២១ នេះ ខណៈ រាជរដ្ឋាភិបាលកំពុងរក្សាទិសដៅកំណើនក្នុងរង្វង់ ៤%-៥% នៅឆ្នាំក្រោយ ជាមួយនឹងការជំរុញការស្តារឡើងវិញនៃសេដ្ឋកិច្ចដែលកំពុងជួបការលំបាកតាមរយៈវិធានការគាំទ្រនានា នេះបើយោងតាមប្រសាសន៍របស់លោក Arkhom Termpittayapaisith រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុថៃ អំឡុងពេលលោកមានវត្តមាននៅក្នុងសិក្ខាសាលាពាណិជ្ជកម្មមួយ។

លោកបានបន្ថែមថា សេដ្ឋកិច្ចថៃបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីការផ្ទុះឡើងនៃមេរោគឆ្លងកូវីដ-១៩ ប៉ុន្តែរាជរដ្ឋាភិបាលបានឆ្លើយតបយ៉ាងឆាប់រហ័សចំពោះមេរោគរាតត្បាតនេះ ជាមួយនឹងវិធានការសារពើពន្ធ និងហិរញ្ញវត្ថុចាំបាច់។

ជាក់ស្តែង ការផ្ទុះឡើងជាថ្មីដ៏អាក្រក់បំផុតនូវមេរោគឆ្លងកូវីដ-១៩ នៅក្នុងខែកក្កដា និងសីហា ឆ្នាំ២០២១ កន្លងមក នៅក្នុងប្រទេសថៃ បាននាំឱ្យមានការរឹតបន្តឹងដ៏តឹងរ៉ឹងជាងមុន និងបានបណ្តាលឱ្យសកម្មភាពសេដ្ឋកិច្ចថមថយ ប៉ុន្តែ ចាប់ពីពេលនោះមក ការទប់ស្កាត់ទាំងនោះត្រូវបានបន្ធូរបន្ថយ។ ទន្ទឹមនឹងនេះ នៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១ អាជ្ញាធរបានយល់ព្រមបើកដំណើរការអាជីវកម្មបន្ថែមទៀត។

លោករដ្ឋមន្ត្រីបានបញ្ជាក់ថា «ជាមួយនឹងដំណើរឆ្ពោះទៅមុខ រាជរដ្ឋាភិបាលនឹងពន្លឿនកិច្ចខិតខំប្រឹងប្រែង និងធ្វើឱ្យសេដ្ឋកិច្ចមានភាពរស់រវើកឡើងវិញ»។ នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានកាត់បន្ថយពិដានបំណុលសាធារណៈដើម្បីឱ្យវិធានការសារពើពន្ធកាន់តែមានភាពបត់បែនបន្ថែមទៀត ដែលនឹងជួយជំរុញដល់កំណើនសេដ្ឋកិច្ច។

ដោយឡែក យោងតាមប្រសាសន៍របស់លោក Sethaput Suthiwartnarueput ទេសាភិបាលធនាគារជាតិថៃ ក្នុងសន្និសិទដាច់ដោយឡែកមួយបានឱ្យដឹងថា សេដ្ឋកិច្ចថៃអាចនឹងមានកំណើនតិចជាង ១% នៅឆ្នាំនេះ ខណៈធនាគារជាតិថៃបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការណែនាំ ឬកែសម្រួលវិធានការតាមតម្រូវការ ដើម្បីជួយដល់ម្ចាស់បំណុល និងអាជីវកម្ម។ ធនាគារជាតិថៃ នឹងពិនិត្យមើលគោលនយោបាយរូបិយវត្ថុ និងធ្វើបច្ចុប្បន្នភាពការព្យាករណ៍សេដ្ឋកិច្ចរបស់ខ្លួន នៅថ្ងៃពុធសប្ដាហ៍នេះ។ ខណៈការព្យាករណ៍កំណើនផ.ស.ស. បច្ចុប្បន្នរបស់ខ្លួនគឺ ០,៧% សម្រាប់ឆ្នាំ២០២១ នេះ៕

*ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ គេហទំព័រសារព័ត៌មាន Reuters ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ ២០២១*

## ពលរដ្ឋសិង្ហបុរីចំនួន ១៦ម៉ឺននាក់ នឹងទទួលបានកាតសម្រាប់ទិញគ្រឿងទេសតម្លៃ ១០០ដុល្លារសិង្ហបុរី នៅក្នុងខែតុលា ឆ្នាំ២០២១ នេះ



*ប្រភព៖ CNA ២០២១, រូបភាព៖ AP Photo/Zen Soo*

យោងតាមសេចក្ដីប្រកាសរបស់ក្រសួងហិរញ្ញវត្ថុសិង្ហបុរី ដែលទើបចេញផ្សាយកាលពីពេលថ្មីៗបានឱ្យដឹងថា ពលរដ្ឋសិង្ហបុរីប្រមាណ ១៦ម៉ឺននាក់ នឹងទទួលបានកាតសម្រាប់ទិញគ្រឿងទេសឆ្នាំ២០២១ ដែលមានតម្លៃ ១០០ដុល្លារសិង្ហបុរី សម្រាប់ចំណាយក្នុងគ្រួសាររបស់ពួកគេ ចាប់ពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០២១ ហើយកាតនេះមានសុពលភាពប្រើប្រាស់រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២។

គម្រោងផ្ដល់ជូនកាតសម្រាប់ទិញគ្រឿងទេសនេះ នឹងផ្ដល់ជំនួយសរុបប្រហែល ៦៣លានដុល្លារសិង្ហបុរី ដល់ពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ប៉ុណ្ណោះ។ ពលរដ្ឋដែលអាចទទួលបានកាតនេះ គឺជាពលរដ្ឋដែលមានអាយុចាប់ពី ២១ឆ្នាំឡើងទៅ កំពុងរស់នៅក្នុងផ្ទះល្វែង (HDB flats) ដែលមាន ១ ឬ២បន្ទប់ និងមិនកាន់កាប់អចលនទ្រព្យលើសពីមួយឡើយ។ កាតនេះអាចត្រូវប្រើប្រាស់បាននៅផ្សារទំនើបលក់ទំនិញ Giant, NTUC FairPrice, Prime និង Sheng Siong។

ជាមួយគ្នានេះ ដើម្បីជំរុញរបៀបរស់នៅឱ្យកាន់តែមានសុខភាពល្អ អ្នកទទួលបានកាតនឹងរីករាយជាមួយការបញ្ចុះតម្លៃ ៥% លើផលិតផលដែលមាននិមិត្តសញ្ញាជម្រើសសុខភាពល្អ (កំណត់ត្រឹម ៥% នៃតម្លៃកាតដែលប្រើប្រាស់សម្រាប់ការទិញ) នៅផ្សារទំនើបលក់ទំនិញ NTUC FairPrice, Prime និង Sheng Siong ខណៈ នៅផ្សារទំនើបលក់ទំនិញ Giant នឹងបញ្ចុះតម្លៃ ៤% លើកន្ត្រកទិញទំនិញរបស់ពួកគេទាំងអស់ (កំណត់ត្រឹម ៤% នៃតម្លៃកាតដែលប្រើប្រាស់សម្រាប់ការទិញ ឬបញ្ចុះតម្លៃ ២ដុល្លារសិង្ហបុរី ក្នុងមួយប្រតិបត្តិការ)។

ក្រសួងបានបញ្ជាក់ថា «នេះគឺជាផ្នែកមួយនៃកញ្ចប់ថែទាំ និងឧបត្ថម្ភ ដែលបានប្រកាសនៅក្នុងកញ្ចប់ថវិកាឆ្នាំ ២០២០ ដើម្បីជួយដល់ពលរដ្ឋសិង្ហបុរីដែលមានជីវភាពមិនសូវធូរធារសម្រាប់ចំណាយក្នុងគ្រួសាររបស់ពួកគេ ក្នុងអំឡុងពេលនៃភាពមិនច្បាស់លាស់ផ្នែកសេដ្ឋកិច្ច»។ នៅក្នុងឆ្នាំ២០២០ កាតសម្រាប់ទិញគ្រឿងទេសតម្លៃ

៣០០ដុល្លារសិង្ហបុរី ត្រូវបានផ្តល់ជូនដល់ពលរដ្ឋដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់៕ *ដោយ ស៊ិន សុភារ៉ា*

*ប្រភព៖ [គេហទំព័រសារព័ត៌មាន Channel News Asia](#) ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០២១*

## កំណើននៃវិស័យសំណង់របស់ម៉ាឡេស៊ី នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១

ទំហំការងារសំណង់ ដែលបានសាងសង់នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ បានកើនឡើង ៤២,៦% ស្មើនឹង ២៨,២ ពាន់លានរីងហ្គីត ធៀបទៅនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។
អនុវិស័យសកម្មភាពពាណិជ្ជកម្មពិសេសមានកំណើន ៧៥% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ បើធៀបទៅនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ទន្ទឹមនឹងនេះ អនុវិស័យបីផ្សេងទៀត គឺវិស្វកម្មសំណង់ស៊ីវិល អគារមិនមែនលំនៅដ្ឋាន និងអគារលំនៅដ្ឋានមានកំណើន ៥៩,៥% ៣៧% និង១៨% រៀងគ្នា បើធៀបនឹងត្រីមាសដូចគ្នាកាលពីឆ្នាំមុន។

នាយកដ្ឋានស្ថិតិម៉ាឡេស៊ីក៏បានរាយការណ៍ផងដែរថា ទំហំការងារសំណង់ ត្រូវបានគ្របដណ្តប់ដោយអនុវិស័យវិស្វកម្មសំណង់ស៊ីវិលចាប់តាំងពីត្រីមាសទី៤ ឆ្នាំ ២០១៥ ដោយមានចំណែក ៤០,៧% បន្ទាប់មកអគារមិនមែនលំនៅដ្ឋានមានចំណែក ២៨,២% អគារលំនៅដ្ឋានមានចំណែក ២២,៦% និងសកម្មភាពពាណិជ្ជកម្មពិសេសមានចំណែក ៨,៦%។
គួរគត់សំគាល់ផងដែរ វិស័យឯកជនបានបន្តចូលរួមជំរុញសកម្មភាពសំណង់ដោយមានចំណែក ៥៣,៧% ស្មើនឹង ១៥,២ ពាន់លានរីងហ្គីត នៃទំហំការងារសំណង់សរុប ធៀបទៅនឹងវិស័យសាធារណៈវិញ មានចំណែកតែ ៤៦,៣% ស្មើនឹង ១៣,១ ពាន់លានរីងហ្គីត៕

*ដោយ ជឹម ប៊ុនធឿន*

| | ត្រីមាសទី២ ឆ្នាំ ២០២១ (កំណើន) |
|---|---|
| សកម្មភាពពាណិជ្ជកម្មពិសេស | 75.0% |
| វិស្វកម្មសំណង់ស៊ីវិល | 59.5% |
| អគារដែលមិនមែនជាលំនៅដ្ឋាន | 37.0% |
| អគារលំនៅដ្ឋាន | 18.0% |

*ប្រភព៖ [Department of Statistics Malaysia Official Portal](#)*

## កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេងរបស់សិង្ហបុរីទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែសីហា ឆ្នាំ២០២១

តារាងខាងក្រោមបង្ហាញពី ការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (NODX: (Non-oil domestic exports) ទៅកាន់ទីផ្សារធំៗទាំង១០ នៅក្នុងខែសីហា ឆ្នាំ២០២១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ NODX ពីសិង្ហបុរីទៅកាន់កោះតៃវ៉ាន់បានកើនឡើង ៥០,៦% នៅ ក្នុងខែសីហា ឆ្នាំ២០២១ ខណៈNODX កាលពីខែមុនកើនតែ ២៨,៦%។ កំណើននេះជំរុញដោយការនាំចេញឧបករណ៍វាស់ស្ទង់(measuring instruments) កើន ១៦៧,៤% ម៉ាស៊ីនឯកទេសកើន ១៥៥,៧% និង Import Certificate (ICs) កើន ១៨,៥%។

NODX ទៅកាន់ហុងកុងបានកើនឡើង ២២,៨% នៅក្នុង ខែសីហា ឆ្នាំ២០២១ បន្ទាប់ពីមានកំណើន ១,២% កាលពីខែកក្កដា ឆ្នាំ២០២១។ ការកើនឡើងនេះដោយសារ ការនាំចេញ electrical circuit apparatus កើន ៩៧,៦% ផលិតផលប្រព័ន្ធ

ផ្សព្វផ្សាយឌីស (disk media products) កើន ៥៤,១% និង ICs កើន ៤៨,៧%។

NODX ទៅកាន់ម៉ាឡេស៊ីបានកើនឡើង ១៧,៩% នៅក្នុង ខែសីហា ឆ្នាំ២០២១ ដោយសារការនាំចេញសារធាតុគីមីសំយោគពីប្រេង ឬឧស្ម័នធម្មជាតិ (petrochemicals) កើន ៦០,៨% diodes & transistors កើន ៥៦,៩% និង ICs កើន ២១,៣%។

ជារួម NODXទៅកាន់ទីផ្សារធំៗទាំង១០ បានកើនឡើង នៅក្នុងខែសីហា ឆ្នាំ២០២១ ទោះបីជា NODXទៅទីផ្សារចិន និងសហគមន៍អឺរ៉ុបបានធ្លាក់ចុះក៏ដោយ។ ទីផ្សារធំបំផុត នៃNODX របស់សិង្ហបុរី គឺតៃវ៉ាន់ (+៥០,៦%) ហុងកុង (+២២,៨%) និងម៉ាឡេស៊ី (+១៧,៩%)៕

*ដោយ ជឹម ប៊ុនធឿន*

| ទីផ្សារធំៗ | កំណើននៃការនាំចេញផលិតផលក្នុងស្រុកមិនមែនប្រេង (%) (ធៀបរយៈពេលដូចគ្នាឆ្នាំមុន) | |
|---|---|---|
| | កក្កដា ឆ្នាំ ២០២១ | សីហា ឆ្នាំ ២០២១ |
| តៃវ៉ាន់ | 37.0 | 50.6 |
| ហុងកុង | 1.2 | 22.8 |
| ម៉ាឡេស៊ី | 3.2 | 17.9 |
| អាមេរិក | -50.7 | 7.6 |
| ថៃ | 30.4 | 24.2 |
| កូរ៉េខាងត្បូង | 5.6 | 18.7 |
| ឥណ្ឌូនេស៊ី | 14.2 | 17.2 |
| ជប៉ុន | 22.5 | 13.9 |
| សហគមន៍អឺរ៉ុប | 61.5 | -20.0 |
| ចិន | 58.4 | -17.5 |

*ប្រភព៖ www.enterprisesg.gov.sg*

## ម៉ាឡេស៊ីដាក់ផែនការ៥ឆ្នាំក្លាយជាប្រទេសចំណូលខ្ពស់




*ប្រភព ៖ ខេមបូឌាមីស*

ប្រទេសម៉ាឡេស៊ី កំពុងកំណត់ទិសដៅកំណើនសេដ្ឋកិច្ចពី ៤,៥% ទៅ ៥,៥% ជាប្រចាំឆ្នាំ ជាមួយនឹងការអនុវត្តផែនការចាប់ពីឆ្នាំ២០២១ ទៅដល់ឆ្នាំ ២០២៥ ជំរុញឱ្យប្រទេសម៉ាឡេស៊ី ក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ និងបច្ចេកវិទ្យាខ្ពស់ ឬហៅថា ផែនការម៉ាឡេស៊ីទី១២។

រដ្ឋាភិបាលនឹងចំណាយជាង ៩៥ ពាន់លានដុល្លារ លើគម្រោងអភិវឌ្ឍន៍ផែនការម៉ាឡេស៊ីទី១២ ដែលមានស្រាប់ និងថ្មី នៅចន្លោះឆ្នាំ២០២១ និង ២០២៥ ដែលនៅក្នុងផែនការម៉ាឡេស៊ីលើកទី១១ បានចំណាយអស់ ៦២ ពាន់លានដុល្លារ។

នៅឆ្នាំ២០២០ ចំណូលពលរដ្ឋម្នាក់ៗនៅក្នុងប្រទេសម៉ាឡេស៊ី មានប្រមាណជាង ១ម៉ឺនដុល្លារអាមេរិក ដែលមានតិចជាង២០% នៃកម្រិតតម្រូវនៃការក្លាយទៅជាប្រទេសចំណូលខ្ពស់ ហើយម៉ាឡេស៊ីរំពឹងថា នៅឆ្នាំ ២០២៥ ម៉ាឡេស៊ីនឹងអាចឈានទៅសម្រេចគោលដៅប្រទេសចំណូលខ្ពស់នេះបាន។

នៅឆ្នាំ២០២០ ឱនភាពថវិការបស់រដ្ឋាភិបាលមានចំនួន ៦,២% នៃផលិតផលក្នុងស្រុកសរុប ខណៈពេលដែលគណៈរដ្ឋមន្ត្រីថ្មីៗនេះ បានស្នើបង្កើនពិដានបំណុលសាធារណៈពីកម្រិត ៦០% ដែលបានកំណត់

កាលពីឆ្នាំមុន ឱ្យឡើងដល់ ៦៥% នៃផលិតផលក្នុងស្រុកសរុប ដើម្បីបង្កើនលទ្ធភាពខ្ចីបំណុលបន្ថែម ដើម្បីស្តារសេដ្ឋកិច្ចឱ្យស្ទុះងើបឡើងវិញ។ នៅឆ្នាំ២០២៣ ហិរញ្ញវត្ថុរបស់រដ្ឋាភិបាលត្រូវបានរំពឹងថា នឹងមានភាពប្រសើរឡើង៕ *ដោយ ម៉ែន ខែមវរៈ*

*ប្រភព៖ខេមបូណ្ឌមីសចេញផ្សាយថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១។*

## សេដ្ឋកិច្ចសកល

### ធនាគារកណ្តាលអាមេរិក រក្សាអត្រាការប្រាក់ឱ្យមានស្ថិរភាព

ធនាគារកណ្តាលអាមេរិក បានរក្សាអត្រាការប្រាក់គោល នៅជិតសូន្យ ប៉ុន្តែបានបង្ហាញថា ការដំឡើងអត្រាការប្រាក់អាចនឹងមកដល់ឆាប់ជាងការរំពឹងទុក ដែលបានកាត់បន្ថយយ៉ាងខ្លាំងនូវទស្សនវិស័យសេដ្ឋកិច្ចរបស់ខ្លួនសម្រាប់ឆ្នាំនេះ។

ទន្ទឹមនឹងការផ្លាស់ប្តូរដែលត្រូវបានរំពឹងទុក មន្ត្រីផ្នែកបង្កើតគោលនយោបាយ នៃគណៈកម្មាធិការទីផ្សារចំហសហព័ន្ធ(FOMC) បានបង្ហាញថាពួកគេនឹងចាប់ផ្តើមដកថយនូវការជំរុញមួយចំនួន ដែលធនាគារកណ្តាលបានផ្តល់ក្នុងកំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ ទោះបីមិនមានការចង្អុលបង្ហាញជាក់លាក់ថា តើនៅពេលណាដែលអាចកើតឡើងនៅឡើយ។ ប្រធានធនាគារកណ្តាល លោក Jerome Powell បាននិយាយនៅក្នុងសន្និសីទសារព័ត៌មានក្រោយកិច្ចប្រជុំរបស់គាត់ថា គណៈកម្មាធិការ នេះបានត្រៀមខ្លួនរួចរាល់ហើយ។

លោក បានបន្តទៀតថា "ទោះបីជាមិនមានការសម្រេចចិត្តក៏ដោយ អ្នកចូលរួមជាទូទៅមើលឃើញថា ដរាបណាការងើបសេដ្ឋកិច្ចឡើងវិញនៅតែបន្តដំណើរការល្អ ការកាត់បន្ថយបន្តិចម្តងៗ ដែលនឹងបញ្ចប់នៅពាក់កណ្តាលឆ្នាំក្រោយទំនងជាស័ក្តសម"។ សម្រាប់ពេលនេះ គណៈកម្មាធិការ បានបោះឆ្នោតជាឯកច្ឆន្ទ ដើម្បីរក្សាអត្រាការប្រាក់រយៈពេលខ្លីនៅជិតសូន្យ។ ទោះយ៉ាងណាក៏ដោយ ឥឡូវនេះសមាជិកកាន់តែច្រើនយល់ឃើញថាការដំឡើងអត្រាការប្រាក់លើកដំបូងនឹងកើតឡើងនៅឆ្នាំ២០២២។ កាលពីខែមិថុនា នៅពេលដែលសមាជិកបានចេញការព្យាករណ៍សេដ្ឋកិច្ចចុងក្រោយរបស់ពួកគេ ភាគច្រើនបានដាក់ការព្យាករណ៍នៃកើនឡើងអត្រាការប្រាក់នេះដល់ឆ្នាំ ២០២៣ ។

ជាមួយគ្នានេះ FOMC មើលឃើញថា ផ.ស.ស កើនឡើងត្រឹមតែ ៥,៩%ប៉ុណ្ណោះក្នុងឆ្នាំនេះ បើប្រៀបធៀបទៅនឹងការព្យាករណ៍ ៧% ក្នុងខែមិថុនា។ ទោះយ៉ាងណា កំណើនឆ្នាំ ២០២២ ឥឡូវនេះ ត្រូវបានកំណត់នៅ ៣,៨% បើប្រៀបធៀបទៅនឹង ៣,៣% ពីមុន និង ២,៥% នៅឆ្នាំ២០២៣ ដែលកើនឡើងមួយភាគដប់នៃមួយពិន្ទុភាគរយ។ ចំពោះការព្យាករណ៍ លើអតិផរណាស្នូល ត្រូវបានព្យាករណ៍ថានឹងកើនឡើង ៣,៧%នៅឆ្នាំនេះ បើប្រៀបធៀបទៅនឹងការព្យាករណ៍កាលពីមុន ៣% ខណៈពេលដែលមន្ត្រី មើលឃើញអតិផរណា ២,៣% នៅឆ្នាំ២០២២ បើប្រៀបធៀបនឹងការព្យាករណ៍មុន ២,១% និង ២,២% នៅឆ្នាំ២០២៣ ដែលមួយភាគដប់ នៃមួយពិន្ទុភាគរយ ខ្ពស់ជាងការព្យាករណ៍ខែមិថុនា។ *ដោយ វត្តា វង្សវឌ្ឍនៈ*

*ប្រភព៖ គេហទំព័រសារព័ត៌មាន CNBC ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១*

### ប្រេងឆៅ Brentឡើងថ្លៃដល់ជាង ៨០ដុល្លារ ដែលជាកម្រិតខ្ពស់ក្នុងកំឡុងពេលជិត ៣ឆ្នាំ

ប្រេងឆៅគោលអន្តរជាតិ ប្រភេទប្រេង Brent បានឡើងថ្លៃជាលើកទី៦ជាប់ៗគ្នា នៅថ្ងៃអង្គារនេះដោយ

លោតខ្ពស់ជាង ៨០ដុល្លារ ក្នុងមួយបារ៉ែលជាលើកដំបូង ចាប់តាំងពីខែតុលាឆ្នាំ ២០១៨ ដោយសារតម្រូវការស្ទុះងើបឡើងវិញ ហើយការផ្គត់ផ្គង់នៅតែរឹតត្បិត។

ជាមួយគ្នានេះ តម្លៃប្រេងឆៅនៅភាគខាងលិចរដ្ឋតិចសាស់ ( West Texas Intermediate crude futures) ដែលជាប្រេងឆៅគោលរបស់អាមេរិក ក៏បានកើនឡើងប្រហែល ១% ដល់កំរិតខ្ពស់បំផុតក្នុងកំឡុងជាងពីរខែ គឺ ៧៦,២៨ ដុល្លារក្នុងមួយបារ៉ែល។ កិច្ចសន្យាទាំងពីរនឹងបញ្ចប់ក្នុងរយៈពេល ៥ សប្តាហ៍ជាប់ៗគ្នា ហើយកិច្ចសន្យានីមួយៗកើនឡើងជាង ៥០% សម្រាប់ឆ្នាំ ២០២១។

ទន្ទឹមនឹងនេះ អ្នកវិភាគនៅ Barclays បានសរសេរកាលពីថ្ងៃអង្គារនៅក្នុងកំណត់សំគាល់មួយទៅកាន់អតិថិជនថា "វិនភាពនៃការផ្គត់ផ្គង់អចិន្ត្រៃយ៍កំពុងនាំឱ្យទីផ្សារប្រេងកាន់តែរឹតត្បិត ដោយសារស្តុករបស់ OECD ទំនងជានឹងបញ្ចប់នៅឆ្នាំនេះក្នុងកម្រិតទាបនៃតម្រូវការគ្របដណ្តប់ក្នុងរយៈពេលជាច្រើនទសវត្សរ៍"។ ក្រុមហ៊ុនបានកំណត់គោលដៅឆ្នាំ ២០២២ របស់ខ្លួនសម្រាប់ WTI និង Brent ដល់ ៧៤ ដុល្លារ និង ៧៧ដុល្លារក្នុងមួយបារ៉ែល។

ចុងក្រោយប្រេងប្រភេទ Brent បានជួញដូរខ្ពស់ជាង ០,៧៧% ក្នុងតម្លៃ ៨០,១៤ ដុល្លារក្នុងមួយបារ៉ែល ហើយក្រុមហ៊ុន Goldman Sachs រំពឹងថាកិច្ចសន្យានេះនឹងឡើងដល់ ៩០ដុល្លារនៅចុងឆ្នាំនេះដោយសារតម្រូវការនៅតែបន្តងើបឡើងវិញ។ ហើយក្រុមហ៊ុន បានដំឡើងគោលដៅរបស់ខ្លួនកាលពីថ្ងៃអាទិត្យដល់ ៩០ ដុល្លារ បន្ទាប់ពីបានព្យាករណ៍ទុកមុនថា Brent មានតម្លៃ ៨០ ដុល្លារនៅចុងឆ្នាំនេះ។*ដោយ វត្ថា វង្សវឌ្ឍនៈ*

*ប្រភព៖ CNBC ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី០៤ ខែតុលា ឆ្នាំ២០២១

- ចំនួនមនុស្សដែលបានចុះឈ្មោះជាអ្នកគ្មានការងារធ្វើនៅក្នុងប្រទេសអេស្ប៉ាញបានធ្លាក់ចុះ នៅខែសីហាឆ្នាំ ២០២១
- កំណើន សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសទួរគី នៅក្នុងខែសីហាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី០៥ ខែតុលា ឆ្នាំ២០២១

- អតិរេកពាណិជ្ជកម្មរបស់អូស្ត្រាលីបានកើនឡើងដល់កំរិតខ្ពស់បំផុតថ្មី ក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើន ផលិតកម្មឧស្សាហកម្មរបស់ប្រទេសបារាំង នៅខែកក្កដាឆ្នាំ ២០២១

ថ្ងៃពុធ ទី០៦ ខែតុលា ឆ្នាំ២០២១

- ការលក់រាយនៅតំបន់ចាយប្រាក់អឺរ៉ូបានធ្លាក់ចុះ ២,៣% នៅក្នុងខែកក្កដាឆ្នាំ ២០២១
- កំណើនការជួលកម្មករក្នុងអាជីវកម្មឯកជននៅអាមេរិក នៅខែសីហាឆ្នាំ ២០២១ បើប្រៀប

ថ្ងៃព្រហស្បតិ៍ ទី០៧ ខែតុលា ឆ្នាំ២០២១

- កំណើន ទុនបំរុងរូបិយប័ណ្ណបរទេសនៅក្នុងប្រទេសរុស្ស៊ី ក្នុងខែសីហា
- ឱនភាពពាណិជ្ជកម្មរបស់ប្រទេសបារាំង នៅក្នុងខែកក្កដាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី០៨ ខែតុលា ឆ្នាំ២០២១

- ការធ្លាក់ចុះ អត្រាអតិផរណាប្រចាំឆ្នាំរបស់ម៉ិកស៊ិក ក្នុងខែសីហាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មនៅប្រទេសអាល្លឺម៉ង់ ក្នុងខែកក្កដាឆ្នាំ ២០២១៕